# ការលម្អកលគ (Kalaśa) នៅក្នុងស្ថាបត្យកម្មខ្មែរ (ភាគ១)

កលគ (Kalaśa) ជាភាសាសំស្ក្រឹតសំដៅដល់ភាជន៍មួយប្រភេទដែលពេលខ្លះមាន សណ្ឋានស្រដៀងនឹងថូទឹក តែពេលខ្លះក៏មានសណ្ឋានជាឆ្នាំងឬក្អមដែរ (រូបលេខ១)។ សព្វថ្ងៃនេះពាក្យ កលគ នេះបានក្លាយមកជាពាក្យខ្មែរបច្ចុប្បន្នថា "ក្លស់"។ កលគ ជានិមិត្តរូបមង្គលមួយប្រភេទដែលមានការរាប់អានខ្លាំងនៅក្នុងសង្គមវប្បធម៌ឥណ្ឌា ដោយយើងអាចមើលឃើញនៅតាមសំណង់ប្រាសាទនានារបស់ឥណ្ឌាតែងមានការលម្អកលគនេះជានិច្ច ឬតាមពិធីផ្សេងៗរបស់ឥណ្ឌាក៏មានប្រើកលគនេះដែរ។ ដោយឡែកក្នុងសង្គមខ្មែរនៅសម័យបុរាណដែលបានទទួលយកឥទ្ធិពលវប្បធម៌យ៉ាងច្រើនពីឥណ្ឌាវិញ ក៏បានទទួលយកគំនិតនៃការប្រើប្រាសកលគជានិមិត្តរូបមង្គលសម្រាប់យកមកលម្អនៅតាមប្រាសាទខ្មែរផងដែរ។




រូបលេខ១៖ - ឆ្វេង: កលគនៅកំពូលប្រាសាទ Shore នៅក្រុង Mahabalipuram, (រូបថត៖ឡេង ស៊ីវ៉ង់)
- ស្តាំ: កលគពីប្រាសាទខ្លាឃ្មុំ ភ្នំគូលែន (រូបថត៖ឡេង ស៊ីវ៉ង់)

ជាទូទៅកលគ ដំណាងឱ្យភាពសម្បូរសប្បាយ ភោគផល កំណើត និងកម្លាំងជីវិតដែលពោរពេញដោយថាមពល។[៩] ហេតុផលមួយដែលបង្ហាញថាកលគតំណាងឱ្យភាព

[៩] Naela Aamir 2016: 561 – 581.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

សម្បូរសប្បាយឬភោគផល មានការពន្យល់ថា កលគជាភាជន៍មួយប្រភេទដែលអាចទាំងដាក់ទឹកបានផង និងអាចទាំងដាក់ដីបានផង ដូចនេះគេអាចដាំដើមរុក្ខជាតិនៅខាងក្នុងនោះបាន (រូបលេខ២២)។ រុក្ខជាតិនោះទៀតសោតក៏មានបេញផ្លែផ្កាពេញដើម ដែលនេះជានិមិត្តនៃភោគផលនិងភាពសម្បូរសប្បាយ។[២] កលគដែលមានរុក្ខជាតិដុះចេញមកនោះ នៅក្នុងសិល្បៈឥណ្ឌាគេហៅថា បូរណកលគ (Pūrṇa Kalaśa) ឬបូរណកុម្ភ (Pūrṇa Kumbha) ឬបូរណឃាត (Pūrṇa Ghaṭa)។



រូបលេខ២២៖ បូរណកលគនៅសារមន្ទីររដ្ឋ Chennai ប្រទេសឥណ្ឌា (រូបថត៖ ឡេង ស៊ីវ៉ង់)

ចំពោះគំនិតដែលបង្ហាញថា កលគតំណាងឱ្យកំណើតនោះយើងអាចឃើញច្បាស់អំពីគំនិតនេះនៅក្នុងរឿងមហាភារតៈត្រង់ឈុតការឱ្យកំណើតបុត្រទាំង១០១របស់ព្រះនាងគន្ធារី (រូបលេខ២៣)។ រឿងនេះដំណាលថា កាលគ្រាមួយព្រះនាងគន្ធារីដែលជាមហេសីរបស់ស្ដេចធឬតរាស្ត្រ បានទទួលពរពីឫសីវ្យាសៈថាឱ្យព្រះនាងមានបុត្រាចំនួន ១០០។ ក្រោមមកព្រះនាងទ្រង់គភ៌បុត្ររហូតដល់ទៅ២ឆ្នាំ ហើយនៅទីបំផុតទ្រង់ប្រសូតបានជាដុំសាច់មួយដុំធំទៅវិញ។ ព្រះនាងបានទៅតវ៉ាឫសីវ្យាសៈអំពីពរដែលឫសីឱ្យព្រះ

[២] Chedha Tingsanchali 2022: 22.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

នាង ជាលទ្ធផលឫសីវ្យាសៈបានបង្គាប់ឱ្យគេយកដុំសាច់នោះមកកាត់ជា១០០ចំណែក ហើយយកទៅដាក់ក្នុងផ្ទាំងដើម្បីធ្វើឱ្យសាច់ទាំងនោះក្លាយជាទារក។ គ្រានោះព្រះនាងគន្ធារីក៏សូមអង្វរឱ្យឫសីជួយឱ្យទ្រង់មានបុត្រីមួយអង្គបន្ថែមទៀត ទើបឫសីវ្យាសៈបានបំបែកសាច់មួយដុំផ្សេងទៀតទៅក្នុងផ្ទាំងទី១០១ដើម្បីធ្វើឱ្យបានទៅជាបុត្រី។[៣] នៅទីបំផុតសាច់ទាំង១០១ដុំនោះក៏បានក្លាយជាទារកហើយកើតចេញមកដែលគេស្គាល់ថាជាបងប្អូនកោរវៈ។ ក្នុងករណីនេះបង្ហាញថាផ្ទាំងទាំងនោះ បានធ្វើនាទីជំនួសឱ្យគភ៌មាតាដែលឱ្យកំណើតបុត្រនោះឯង។



រូបលេខ៣៖ គំនូរឫសីវ្យាសៈធ្វើពីធីឱ្យបុត្រទាំង១០១របស់ព្រះនាងគន្ធារី (រូបថត៖ https://bit.ly/3MyLhJt)

ចំពោះគំនិតមួយដែលថាកលគមានទំនាក់ទំនងទៅនឹងកម្លាំងជីវិតដែលពោរពេញដោយថាមពល ឬសេចក្តីអមតៈ យើងអាចឃើញបានយ៉ាងច្បាស់នៅក្នុងទេវកថារឿងកូរសមុទ្រទឹកដោះរបស់ពួកទេវនិងអសុរ។ គោលបំណងសំខាន់នៃការកូរសមុទ្រទឹកដោះ

[៣] សូមអានពត៌មានលម្អិតនៅ https://www.worldhistory.org/Kauravas/

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

នេះគឺដើម្បីបានទឹកអម្រឹតដែលធ្វើឱ្យមានមហិទ្ធិឫទ្ធិនិងជីវិតអមតៈ ហើយការលេចឡើងរបស់ទឹកអម្រឹតនេះទៀតសោតក៏កើតចេញក្នុងរូបភាពជារូបថូទឹកឬផ្ដាំងដែលជាកលគផងដែរ (រូបលេខ២៤)។ ដោយហេតុថា កលគជាឧបករណ៍សម្រាប់ដាក់ទឹកអម្រឹតនេះហើយ ទើបធ្វើឱ្យកលគក៏ក្លាយជានិមិត្តរូបនៃកម្លាំងជីវិតដែលពោរពេញដោយថាមពល និងជីវិតអមតដែរ។



រូបលេខ២៤៖ ចម្លាក់រឿងកូរសមុទ្រទឹកដោះនៅប្រាសាទព្រះវិហារ (រូបថត៖ ឡេង ស៊ីវ៉េង)

ដោយហេតុថាកលគជានិមិត្តរូបនៃភាពសម្បូរសប្បាយ ភោគផល កំណើត និងកម្លាំងជីវិតដែលពោរពេញដោយថាមពល ដែលសុទ្ធសឹងតែជារឿងមង្គលបែបនេះហើយ ទើបរូបកលគបានក្លាយជារបស់សំខាន់មួយដែលគេនាំយកទៅលម្អនៅតាមប្រាសាទស្ទើរតែគ្រប់ផ្នែកទាំងអស់នៃប្រាសាទខ្មែរ៕

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

# បញ្ជីឯកសារយោង


Naela Aamir

*The Conceptual, Cultural and Artistic Significance of Purna-Kalasa and its Use in Hindu and Muslim Architecture of the Subcontinent" in A Research Journal of South Asian Studies, Vol. 31, No. 2, July – December 2016, pp.561 – 581)*

Joshi, Nikul.

(2016, August 26). *Kauravas*. World History Encyclopedia. Retrieved from https://www.worldhistory.org/Kauravas/

Tingsanchali, Chedha.

2022. *Temple in Southeast Asia*. Matichon, Bangkok.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ឡេង ស៊ីរ៉ង់